ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៨៤ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# អត្រាសួយសារលើតម្លៃធនធានរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យ លេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យ លេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល ។

# សម្រេច

**ប្រការ ១.-**

សម្បទានិកដែលទទួលអាជ្ញាបណ្ណធនធានរ៉ែទាំងអស់ លើកលែងតែអាជ្ញាបណ្ណស្វែងរុករក និង អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ត្រូវបង់ជូនរដ្ឋនូវសួយសារលើតម្លៃធនធានរ៉ែ (ឬ ហៅកាត់ថា "សួយសារ") ដែលទាញយកបានស្របតាមការកំណត់ក្នុងប្រកាសនេះ ។

**ប្រការ ២.-**

អត្រាសួយសារលើតម្លៃធនធានរ៉ែ ត្រូវកំណត់ដូចខាងក្រោម៖

**ក./ ធនធានរ៉ែសំណង់ (គិតលើបរិមាណផលិតនៅអណ្តូងរ៉ែ)**

| ល.រ | ផលិតផលធនធានរ៉ែ | អត្រាសួយសារ | មូលដ្ឋាន និងលក្ខខណ្ឌសម្រាប់ការគណនា |
|---|---|---|---|
| ១ | ថ្មបំបែកគ្រប់ប្រភេទ | ០.៧៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រត្រីគុណ | ក្នុងករណីថ្លៃមធ្យមនៃផលិតផលថ្ម ១x២ស.ម លើទីផ្សារ ទាបជាង ២០ដុល្លារអាមេរិក/ម៣ |
| | | ១ ដុល្លារអាមេរិកក្នុងមួយម៉ែត្រត្រីគុណ | ក្នុងករណីថ្លៃមធ្យមនៃផលិតផល ថ្ម ១x២ស.ម លើទីផ្សារខ្ពស់ជាង ២០ដុល្លារអាមេរិក/ម៣ |
| ២ | ក្រួសក្រាវែល | ០.៥៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រត្រីគុណ | ក្នុងករណីថ្លៃមធ្យមនៃផលិតផលក្រួសក្រាវែល លើទីផ្សារទាបជាង ២០ដុល្លារអាម៉េរិក/ម៣ |
| | | ០.៨៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រត្រីគុណ | ក្នុងករណីថ្លៃមធ្យមនៃផលិតផលក្រួសក្រាវែល លើទីផ្សារខ្ពស់ជាង ២០ដុល្លារអាម៉េរិក/ម៣ |
| ៣ | ខ្សាច់សំណង់ ខ្សាច់ភ្នំ ដីក្រហម(ឡាតេរីត) និង រ៉ែសំណង់មានគុណភាពប្រហាក់ប្រហែល | ០.២៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រត្រីគុណ | ក្នុងករណីថ្លៃមធ្យមនៃផលិតផលខ្សាច់សំណង់លើទីផ្សារទាបជាង ១៥ដុល្លារអាមេរិក/ម៣ |
| | | ០.៥០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រត្រីគុណ | ក្នុងករណីថ្លៃមធ្យមនៃផលិតផលខ្សាច់សំណង់ លើទីផ្សារខ្ពស់ជាង ១៥ដុល្លារអាមេរិក/ម៣ |
| ៤ | ខ្សាច់សំណង់ និង ខ្សាច់ល្បាយភក់ក្នុងបំណងនាំចេញ | ០.៨៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រត្រីគុណ | ក្នុងករណីថ្លៃមធ្យមនៃផលិតផលអាចម៍ដីលើទីផ្សារទាបជាង ៥ដុល្លារអាមេរិក/ម៣ |
| | | ១.៥០ដុល្លារអាមេរិក ក្នុងមួយម៉ែត្រត្រីគុណ | ក្នុងករណីថ្លៃមធ្យមនៃផលិតផលអាចម៍ដីលើទីផ្សារខ្ពស់ជាង ៥ដុល្លារអាមេរិក/ម៣ |
| ៥ | ដីល្បាប់ ដីល្បាយខ្សាច់ ដីល្បាយដីឥដ្ឋ ដីឥដ្ឋ | ០.១០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រត្រីគុណ | ក្នុងករណីថ្លៃមធ្យមនៃផលិតផលអាចម៍ដីលើទីផ្សារទាបជាង ៥ដុល្លារអាមេរិក/ម៣ |
| | | ០.២០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រត្រីគុណ | ក្នុងករណីថ្លៃមធ្យមនៃផលិតផលអាចម៍ដីលើទីផ្សារខ្ពស់ជាង ៥ដុល្លារអាមេរិក/ម៣ |

| | | | |
|---|---|---|---|
| ៦ | ឡាតេរីតអារ | ៥.៦០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | ក្នុងករណីថ្លៃលក់ផលិតផលឡាតេរីតអារ លើទីផ្សារ (Arm's Length Price) ទាបជាង ២០ ដុល្លារអាមេរិក/ម៣ |
| | | ៧.០០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | ក្នុងករណីថ្លៃលក់ផលិតផលឡាតេរីតអារ លើទីផ្សារ(Arm's Length Price) ខ្ពស់ជាង ២០ដុល្លារអាមេរិក/ម៣ |
| ៧ | ថ្មម៉ាប (ប្លុក ឬ អារ) | ៧.៥ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | ក្នុងករណីថ្លៃលក់ផលិតផលថ្មម៉ាប លើទីផ្សារ (Arm's Length Price) ទាបជាង ២០ ដុល្លារអាមេរិក/ម២ |
| | | ២៥ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | ក្នុងករណីថ្លៃលក់ផលិតផលថ្មម៉ាបលើទីផ្សារ (Arm's Length Price) ពី២០ ទៅ៤០ដុល្លារអាមេរិក/ម២ |
| | | ៤៥ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | ក្នុងករណីថ្លៃលក់ផលិតផលថ្មម៉ាប លើទីផ្សារ (Arm's Length Price) ពី៤០ ទៅ៧០ដុល្លារអាមេរិក/ម២ |
| | | ៦៨ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | ក្នុងករណីថ្លៃលក់ផលិតផលថ្មម៉ាប លើទីផ្សារ (Arm's Length Price) ខ្ពស់ជាង ៧០ដុល្លារអាមេរិក/ម២ |
| ៨ | ថ្មប្លុកក្នុងគោលបំណងនាំចេញ | ២៥ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | ក្នុងករណីថ្លៃលក់ថ្មប្លុកលើទីផ្សារ (Arm's Length Price) មានតម្លៃទាបជាង៥០០ដុល្លារអាមេរិក/ម៣ |
| | | ៧៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | ក្នុងករណីថ្លៃលក់ថ្មប្លុកលើទីផ្សារ (Arm's Length Price) មានតម្លៃពី ៥០០ ទៅ ១ ០០០ ដុល្លារអាមេរិក/ម៣ |
| | | ១៤០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | ក្នុងករណីថ្លៃលក់ថ្មប្លុកលើទីផ្សារ (Arm's Length Price) មានតម្លៃពី ១ ០០០ ទៅ ១ ៧៥០ ដុល្លារ អាមេរិក/ម៣ |
| | | ២២០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | ក្នុងករណីថ្លៃលក់ថ្មប្លុកលើទីផ្សារ (Arm's Length Price) ខ្ពស់ជាង ១ ៧៥០ ដុល្លារអាមេរិក/ម៣ |
| ៩ | ប៉ាហ្គោឌីត (ថ្មកែវ) | ៤៣.៧៥ដុល្លារអាមេរិកក្នុងមួយម៉ែត្រគ្រីគុណ ឬ១៧.៥០ដុល្លារអាមេរិកក្នុងមួយតោន | ក្នុងករណីថ្លៃមធ្យមនៃផលិតផលថ្មកែវលើទីផ្សារទាបជាង ២ ០០០ រៀល/គីឡូក្រាម |
| | | ៥៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ ឬ ២០ ដុល្លារអាមេរិក ក្នុងមួយតោន | ក្នុងករណីថ្លៃមធ្យមនៃផលិតផលថ្មកែវលើទីផ្សារខ្ពស់ជាង ២ ០០០ រៀល/គីឡូក្រាម |

ខ./ ធនធានរ៉ែឧស្សាហកម្ម

| ល.រ | ផលិតផលធនធានរ៉ែ | អត្រាសួយសារ | មូលដ្ឋាន និងលក្ខខណ្ឌសម្រាប់ការគណនា |
|---|---|---|---|
| ១ | ត្បូងថ្ម | ៧ ភាគរយ | គិតលើបរិមាណលក់លើទីផ្សារក្នុងករណីថ្លៃលក់ផលិតផលត្បូងថ្មលើទីផ្សារ (Arm's Length Price)ទាបជាង ១០០ ដុល្លាអាមេរិក/តោន |
| | | ៨.៥០ ភាគរយ | គិតលើបរិមាណលក់លើទីផ្សារក្នុងករណីថ្លក់ផលិតផល ត្បូងថ្មលើទីផ្សារ (Arm's Length Price) ពី១០០ ទៅ ១៥០ដុល្លារអាមេរិក/តោន |
| | | ១០ ភាគរយ | គិតលើបរិមាណលក់លើទីផ្សារក្នុងករណីថ្លៃលក់ផលិតផលត្បូងថ្មលើទីផ្សារ (Arm's Length Price)ខ្ពស់ជាង ១៥០ ដុល្លាអាមេរិក/តោន |
| ២ | ដីឥដ្ឋ កុលាលភាជន៍ | ១០ ភាគរយ | នៃចំណូលដុលពីការលក់លើទីផ្សារ (Arm's Length Price) |
| ៣ | ថ្មកំបោរ និងដូឡូមីត (ប្រើប្រាស់ក្នុងវិស័យកសិកម្ម ឧស្សាហកម្ម) | ០.៦០ ដុល្លារអាមេរិកក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃមធ្យម នៃផលិតផល ស៊ីម៉ង់ត៍ លើទីផ្សារទាបជាង ១៥០ដុល្លារអាមេរិក/តោន |
| | | ០.៨០ ដុល្លារអាមេរិកក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃមធ្យមនៃផលិតផល ស៊ីម៉ង់ត៍លើទីផ្សារខ្ពស់ជាង ១៥០ដុល្លារ អាមេរិក/តោន |
| ៤ | ថ្មកំបោរ (ប្រើប្រាស់ក្នុងវិស័យលោហៈឧស្សាហកម្ម) | ១.៥០ ដុល្លារអាមេរិកក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃមធ្យមនៃផលិតផល ស៊ីម៉ង់ត៍លើទីផ្សារទាបជាង១៥០ដុល្លារ អាមេរិក/តោន |
| | | ២.០០ ដុល្លារអាមេរិកក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃមធ្យមនៃផលិតផល ស៊ីម៉ង់ត៍លើទីផ្សារខ្ពស់ជាង១៥០ដុល្លារ អាមេរិក/តោន |

| | | | |
|---|---|---|---|
| ៥ | ផូស្វាត | ១.៥០ ដុល្លារអាមេរិក ក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃមធ្យមនៃផលិតផលជីផូស្វាត លើទីផ្សារទាបជាង១០០ដុល្លារ អាមេរិក/តោន |
| | | ២.០០ ដុល្លារអាមេរិក ក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃមធ្យមនៃផលិតផលជីផូស្វាតលើទីផ្សារខ្ពស់ជាង១០០ដុល្លារ អាមេរិក/តោន |
| ៦ | ខ្សាច់ស៊ីលីស | ៣.០០ ដុល្លារអាមេរិក ក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃលក់ផលិតផលខ្សាច់ស៊ីលីសលើទីផ្សារ (Arm's Length Price) ទាបជាង២០ដុល្លារអាមេរិក/តោន |
| | | ៥.០០ ដុល្លារអាមេរិក ក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃលក់ផលិតផលខ្សាច់ស៊ីលីសលើទីផ្សារ (Arm's Length Price) ខ្ពស់ជាង២០ដុល្លារអាមេរិក/តោន |
| ៧ | ទឹកក្តៅក្រោមដីនិងទឹកខនិជ | ២ ភាគរយ | នៃចំណូលដុលពីការលក់លើទីផ្សារ (Arm's Length Price) |
| ៨ | បុកស៊ីតសម្រាប់ឧស្សាហកម្មក្នុងស្រុក | ៧.៥០ ភាគរយ | នៃចំណូលដុលពីការលក់លើទីផ្សារ (Arm's Length Price) |
| ៩ | បុកស៊ីតសម្រាប់នាំចេញ | ១០ ភាគរយ | នៃចំណូលដុលពីការលក់លើទីផ្សារ (Arm's Length Price) |

**គ./ ត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ និងគុណភាពប្រហាក់ប្រហែល**

| លរ | ផលិតផលធនធានរ៉ែ | អត្រាសួយសារ | មូលដ្ឋាននិងលក្ខខណ្ឌសម្រាប់ការគណនា |
|---|---|---|---|
| ១ | ត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ និងគុណភាពប្រហាក់ប្រហែល (ចំពោះ: ប្រភេទឧស្សាហកម្ម) | ១៥ ភាគរយ | ចំណូលដុលពីការលក់លើទីផ្សារ (Arm's Length Price) |

| | | | |
|---|---|---|---|
| ២ | ត្បូងថ្មមានតម្លៃ ពាក់កណ្ដាលមានតម្លៃ និងគុណភាពប្រហាក់ប្រហែល (ចំពោះការប្រកបអាជីវកម្មជាលក្ខណៈគ្រួសាររបស់ប្រជាពលរដ្ឋខ្មែរ) | ២០០០ ដុល្លារអាមេរិកក្នុងមួយហិកតា | ផ្ទៃក្រឡាដែលធ្វើអាជីវកម្ម |

**ឃ./ ធនធានរ៉ែលោហៈ**

| ល.រ | ផលិតផលធនធានរ៉ែ | អត្រាសួយសារ | មូលដ្ឋាននិងលក្ខខណ្ឌសម្រាប់ការគណនា |
|---|---|---|---|
| ១ | ធនធានរ៉ែលោហៈរួមទាំងលោហៈមូលដ្ឋាន លោហៈកំរ និងប្រភេទប្រហាក់ប្រហែល | ៣ ភាគរយ | ចំណូលដុលពីការលក់លោហធាតុ (metals)លើទីផ្សារ (Arm's Length Price) |
| | | ៦ ភាគរយ | ចំណូលដុលពីការលក់កំហាប់រ៉ែ (Concentrate)លើទីផ្សារ (Arm's Length Price) |
| | | ៨ ភាគរយ | ចំណូលដុលពីការលក់រ៉ែឆៅ (Crude Ore)លើទីផ្សារ (Arm's Length Price) |

**ប្រការ ៣.-**

អនុលោមតាមច្បាប់ស្ដីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល ចំណូលសួយសារពីធនធានរ៉ែ ត្រូវធ្វើការបែងចែក និងកត់ត្រាក្នុងខ្ទង់ចំណូលដូចមាន កំណត់ខាងក្រោម៖

**ក./ការបែងចែក និងការកត់ត្រា ចំណូលសួយសារលើតម្លៃធនធានរ៉ែ ៖**

ក./១.ចំណូលពីសួយសារលើតម្លៃធនធានរ៉ែថ្មសម្ភារៈសំណង់ ដូចមានកំណត់ក្នុងប្រការ ២ ចំណុច (ក) មានលេខរៀងពី ១ ដល់ ៥ ត្រូវបែងចែកជា ៣ផ្នែករួមមាន៖

-ចំនួន ៧២% (ចិតសិបពីរភាគរយ) នៃចំណូលសួយសារលើតម្លៃធនធានរ៉ែ ត្រូវបង់ និងកត់ត្រាក្នុងចំណូលរបស់ថ្នាក់ជាតិ

-ចំនួន ១៨% (ដប់ប្រាំបីភាគរយ) នៃចំណូលសួយសារលើតម្លៃធនធានរ៉ែ ត្រូវបង់ និងកត់ត្រាក្នុងចំណូលរបស់ថ្នាក់ក្រោមជាតិ

-ចំនួន ១០% (ដប់ភាគរយ) នៃចំណូលសួយសារលើតម្លៃធនធានរ៉ែ ត្រូវបង់ និងកត់ត្រាក្នុងចំណូលកាត់ទុក ។

ក./២.ចំណូលសួយសារលើតម្លៃធនធានរ៉ែ ដូចមានកំណត់ក្នុងប្រការ ២ ចំណុច (ក) មានលេខរៀងពី ៦ ដល់ ៩ ចំណុច (ខ) ចំណុច (គ) និង ចំណុច (ឃ) ត្រូវបែងចែកជា២ផ្នែក រួមមាន ៖

-ចំនួន ៩០% (កៅសិបភាគរយ) នៃចំណូលសួយសារលើតម្លៃធនធានរ៉ែ ត្រូវបង់ និងកត់ត្រាក្នុងចំណូលរបស់ថ្នាក់ជាតិ

-ចំនួន ១០% (ដប់ភាគរយ) នៃចំណូលសួយសារលើតម្លៃធនធានរ៉ែត្រូវបង់ និងកត់ត្រាក្នុងចំណូលកាត់ទុក ។

ខ./ បែបបទនៃការបង់ចំណូលសួយសារលើតម្លៃធនធានរ៉ែ៖

-សម្បទានិកដែលដល់កាលកំណត់ត្រូវបង់ចំណូលសួយសារ ស្របតាមប្រការ ៤ ខាងក្រោម ត្រូវធ្វើការប្រកាសសួយសារ នៅក្រសួងរ៉ែ និងថាមពល (អគ្គនាយកដ្ឋានធនធានរ៉ែ) ឬ មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត ដើម្បីទទួលយកលិខិតបញ្ជាក់បង់ប្រាក់ចំណូលសួយសារលើតម្លៃធនធានរ៉ែ

-បន្ទាប់ពីទទួលលិខិតប្រកាសសួយសារពីសម្បទានិក អំពីការបង់ចំណូលសួយសារលើតម្លៃធនធានរ៉ែ ក្រសួងរ៉ែ និងថាមពល (អគ្គនាយកដ្ឋានធនធានរ៉ែ) ឬមន្ទីររ៉ែ និងថាមពលរាជធានី-ខេត្តត្រូវចេញលិខិតបញ្ជាក់បង់ប្រាក់នៃចំណូលនេះ ទៅធនាគារជាតិនៃកម្ពុជា (សម្រាប់ករណីបង់ប្រាក់នៅរាជធានីភ្នំពេញ) ឬ សាខាធនាគារកាណាឌីយ៉ា សាខាធនាគារពាណិជ្ជ សាខាធនាគារអេស៊ីលីដា (សម្រាប់ករណីបង់ប្រាក់នៅតាមបណ្តាខេត្ត) ជូនសម្បទានិក ។ លិខិតបញ្ជាក់បង់ប្រាក់ ត្រូវមានការបែងចែកច្បាស់លាស់អំពីយថាប្រភេទនៃខ្ទង់ចំណូល ជាចំណូលថ្នាក់ជាតិ ចំណូលថ្នាក់ក្រោមជាតិ និង ចំណូលកាត់ទុក ដូចមានចែងនៅក្នុងប្រការ ៣ ចំណុច (ក) និងត្រូវមានការកំណត់កាលបរិច្ឆេទបង់ប្រាក់ មិនឲ្យលើសពី ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានលិខិតបញ្ជាក់បង់ប្រាក់ ។

-ក្នុងករណីចាំបាច់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ក្រុមការងារទារបំណុលអន្តរក្រសួងមានសមត្ថកិច្ចក្នុងការចេញលិខិតបញ្ជាក់បង់ប្រាក់ជូនត្រង់ទៅសម្បទានិកឲ្យបង់ចំណូលនេះ ដោយមានបញ្ជាក់ការបង់ប្រាក់ដូចមានចែងនៅក្នុង ប្រការ ៣ ចំណុច (ក) ទៅធនាគារជាតិនៃកម្ពុជា (សម្រាប់ករណីបង់ប្រាក់នៅរាជធានីភ្នំពេញ) ឬ សាខាធនាគារកាណាឌីយ៉ា សាខាធនាគារពាណិជ្ជ សាខាធនាគារអេស៊ីលីដា (សម្រាប់ករណីបង់ប្រាក់នៅតាមបណ្តាខេត្ត ) ។ លិខិតបញ្ជាក់បង់ប្រាក់ ត្រូវមានការកំណត់កាលបរិច្ឆេទបង់ប្រាក់មិនឲ្យលើសពី ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានលិខិតបញ្ជាក់បង់ប្រាក់ ។

-បន្ទាប់ពីទទួលយកលិខិតបញ្ជាក់បង់ប្រាក់ ពីក្រសួងរ៉ែ និងថាមពល (អគ្គនាយកដ្ឋានធនធានរ៉ែ) ឬពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក្រុមការងារទារបំណុលអន្តរក្រសួង) ឬ

មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត សម្បទានិកត្រូវបង់ចំណូលសួយសារលើតម្លៃធនធានរ៉ែ ដោយបង់ត្រង់ចូលគណនីដែលមានកំណត់នៅក្នុងលិខិតបញ្ជាក់បង់ប្រាក់។

គ./ការជូនព័ត៌មានស្តីពីការបង់ប្រាក់៖ ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានបង់ចំណូលសួយសារលើតម្លៃធនធានរ៉ែតាមលិខិតបញ្ជាក់បង់ប្រាក់ សម្បទានិកត្រូវផ្តល់ប័ណ្ណបង់ប្រាក់ ឬ ប្រកាសឥណទាន។ល។ ជាច្បាប់ថតចម្លងជូន៖

-ក្រសួងរ៉ែ និងថាមពល ចំនួន១(មួយ)ច្បាប់ ចំពោះសម្បទានិកបង់ប្រាក់តាមលិខិតបញ្ជាក់បង់ប្រាក់ ដែលចេញដោយក្រសួងរ៉ែ និងថាមពល

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក្រុមការងារទារបំណុលអន្តរក្រសួង) ចំនួន១ (មួយ) ច្បាប់ ចំពោះសម្បទានិក បង់ប្រាក់តាមលិខិតបញ្ជាក់បង់ប្រាក់ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-មន្ទីររ៉ែ និងថាមពល និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី-ខេត្តចំនួន១(មួយ)ច្បាប់ៗ ចំពោះសម្បទានិកបង់ប្រាក់តាមលិខិតបញ្ជាក់បង់ប្រាក់ចេញដោយមន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត ។

**ប្រការ ៤.~**

សួយសារលើតម្លៃធនធានរ៉ែ ត្រូវបង់ប្រចាំត្រីមាសនីមួយៗ ដូចខាងក្រោម៖

ក./សម្បទានិក ជាប់កាតព្វកិច្ចបង់សួយសារត្រូវរៀបចំ និងដាក់ជូនរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល តាមរយៈប្រធានមន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត នូវគម្រោងផែនការអាជីវកម្មផលិតកម្ម និងផែនការបង់សួយសារប្រចាំត្រីមាស ហើយត្រូវបង់ជាមុននូវប្រាក់រំដោះសួយសារលើតម្លៃធនធានរ៉ែប្រចាំត្រីមាស ផ្អែកតាមផែនការនៃត្រីមាសនីមួយៗ ឲ្យបានមុនថ្ងៃទី១៥ ខែមករា, ថ្ងៃទី១៥ ខែមេសា, ថ្ងៃទី១៥ ខែកក្កដា, និងថ្ងៃទី១៥ ខែតុលា ជាកំហិត ។

ខ./សម្បទានិក ជាប់កាតព្វកិច្ចបង់សួយសារ ត្រូវប្រកាសថ្លៃសួយសាររ៉ែ លើបរិមាណដែលបានផលិត ឬបានទាញយកធនធានរ៉ែជាក់ស្តែង រៀងរាល់ត្រីមាសនីមួយៗ និងត្រូវធ្វើការទូទាត់ កាត់កងចំនួនប្រាក់លំអៀង រវាងប្រាក់រំដោះចំណូលសួយសារលើធនធានរ៉ែ ដែលបានបង់មុនតាមផែនការអាជីវកម្មប្រចាំត្រីមាស ដូចកំណត់ក្នុងប្រការ ៤ ចំណុច (ក) ទៅនឹងសួយសារលើតម្លៃធនធានរ៉ែ ដែលត្រូវបង់ជាក់ស្តែងតាមបរិមាណធនធានរ៉ែ ដែលផលិត ឬទាញយកបានប្រចាំត្រីមាស របស់សម្បទានិក ស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

ខ./១-ករណីប្រាក់រំដោះ ដែលបានបង់មុនតាមផែនការអាជីវកម្មប្រចាំត្រីមាស តិចជាងចំណូលសួយសារលើតម្លៃធនធានរ៉ែ តាមបរិមាណធនធានរ៉ែដែលផលិត ឬទាញយកបានជាក់ស្តែងប្រចាំត្រីមាស នោះសម្បទានិកមានកាតព្វកិច្ចត្រូវបង់បង្គ្រប់ ។

ខ./២-ករណីប្រាក់រំដោះ ដែលបានបង់មុនតាមផែនការអាជីវកម្មប្រចាំត្រីមាស ច្រើនជាងថ្លៃសួយសារលើតម្លៃធនធានរ៉ែ តាមបរិមាណធនធានរ៉ែ ដែលផលិត ឬទាញយកបានជាក់ស្តែងប្រចាំត្រីមាស ហើយអាជ្ញាបណ្ណធនធានរ៉ែ ក៏នៅមានសុពលភាពនោះ ចំនួនប្រាក់រំដោះថ្លៃសួយសារ ដែលបានបង់លើស ត្រូវបានអនុញ្ញាតឲ្យបូកយោងទៅត្រីមាសបន្ទាប់ ។

ខ./៣-ករណីប្រាក់រំដោះថ្លៃសួយសារដែលបានបង់មុនតាមផែនការអាជីវកម្មប្រចាំត្រីមាសច្រើនជាងថ្លៃសួយសារតាមបរិមាណធនធានរ៉ែដែលផលិត ឬទាញយកបានជាក់ស្តែងប្រចាំត្រីមាស ប៉ុន្តែអាជ្ញាបណ្ណធនធានរ៉ែត្រូវបានដកហូតឬត្រូវបានបញ្ចប់ នោះចំនួនប្រាក់រំដោះថ្លៃសួយសារ ដែលសម្បទានិកបានបង់លើស ត្រូវចាត់ទុកជាប្រយោជន៍ថវិការដ្ឋ ។

គ./ការប្រកាសថ្លៃសួយសារ ត្រូវរៀបចំតាមទម្រង់បែបបទកំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និងត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ដែលបង្ហាញលំអិតអំពី៖
-បរិមាណផលិតផលរ៉ែ
-កិច្ចព្រមព្រៀង ឬកិច្ចសន្យាលក់ និងព័ត៌មានរបស់ភាគីពាក់ព័ន្ធការទិញលក់ទាំងអស់
-ថ្លៃ ឬថ្លៃមូលដ្ឋានសម្រាប់គណនាសួយសារ
-វិក្កយបត្រលក់ សក្ខីបត្រទូទាត់ និងការបញ្ចុះថ្លៃផ្សេងៗ
-វិធីសាស្ត្រ និងរបៀបគណនាសួយសារ និង
-ព័ត៌មានចាំបាច់ផ្សេងៗទៀត សម្រាប់ការគណនាថ្លៃសួយសារ ។

**ប្រការ ៥.-**

ដោយផ្អែកលើទិន្នន័យនៃការសិក្សាតម្លៃធនធានរ៉ែក្នុងទីផ្សារជាក់ស្តែង និង គុណភាពធនធានរ៉ែ ក្រសួងរ៉ែ និងថាមពល ត្រូវធ្វើតារាងសន្ទស្សន៍ស្តីពីស្ថានភាពតម្លៃផលិតផលរ៉ែប្រចាំឆ្នាំនា អំឡុងខែតុលា។ ទិន្នន័យនេះ គឺជាមូលដ្ឋាន និងលក្ខខណ្ឌសម្រាប់ការគណនាសួយសារ និងជាមូលដ្ឋានសម្រាប់ការកែសម្រួលអត្រាសួយសារលើតម្លៃធនធានរ៉ែ តាមការចាំបាច់ និងយ៉ាងយូរបំផុតរៀងរាល់ ៣(បី)ឆ្នាំម្តង ។

**ប្រការ ៦.-**

ករណីប្រាក់រំដោះថ្លៃសួយសារ ដែលបានបង់មុនតិចជាងថ្លៃសួយសារ ដែលបានប្រកាសប្រចាំត្រីមាស ហើយសម្បទានិកខកខានមិនបានបង់ថ្លៃសួយសារ ឬមិនបានបង់បង្គ្រប់នូវប្រាក់ថ្លៃសួយសារដែលខ្វះ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុង ប្រការ ៤ ចំណុច (ក) សម្បទានិកត្រូវទទួលវិធានការតឹងទារថ្លៃសួយសារស្របតាមច្បាប់ និងបទបញ្ញត្តិជាធរមាន ។

**ប្រការ ៧.~**

មន្ទីររ៉ែ និងថាមពល ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តចំណូលសួយសារលើតម្លៃធនធានរ៉ែប្រចាំខែ ជូនមកក្រសួងរ៉ែ និងថាមពល និងចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវឯកសារបង់ចំណូលទាំងអស់ ។

**ប្រការ ៨.~**

ក្រៅពីកាតព្វកិច្ចបង់សួយសារលើតម្លៃធនធានរ៉ែ សម្បទានិកត្រូវមានកាតព្វកិច្ចបង់ពន្ធអាករដទៃទៀត ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**ប្រការ ៩.~**

ក./កាតព្វកិច្ចហិរញ្ញវត្ថុពាក់ព័ន្ធនឹងសួយសារលើតម្លៃធនធានរ៉ែ ដែលមានចែងក្នុងកិច្ចព្រមព្រៀង ឬ ឯកសារផ្សេងៗកន្លងមក ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ លើកលែងតែករណី កិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិ ដែលទទួលបានគោលការណ៍ឯកភាពពីរាជរដ្ឋាភិបាល ឬកាតព្វកិច្ចហិរញ្ញវត្ថុនោះ ជាបដិភាគរបស់រាជរដ្ឋាភិបាល ។

ខ./រាល់ការអនុញ្ញាតឲ្យលើកលែងការបង់ថ្លៃសួយសារ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល តាមការពិនិត្យ និងលើកយោបល់ស្នើសុំការពិនិត្យសម្រេច ពីក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គ./ទោះបីទទួលបានការអនុញ្ញាតលើកលែងការបង់ថ្លៃសួយសារ ពីរាជរដ្ឋាភិបាល ក៏សម្បទានិក នៅតែមានកាតព្វកិច្ចក្នុងការប្រកាសបន្ទុកសួយសារតាមការកំណត់នៅក្នុងចំណុច (គ) ប្រការ ៤ នៃប្រកាសនេះ ។

**ប្រការ ១០.~**

ប្រកាសអន្តរក្រសួង លេខ ០០៦ ប្រក.សហវ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ ស្តីពីការកំណត់ថ្លៃវត្ថុធាតុដើមថ្មសម្ភារសំណង់ ប្រកាសអន្តរក្រសួង លេខ ៩៣៤ សហវ.ប្រក ចុះថ្ងៃ ទី០៨ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកំណត់សួយសារខ្សាច់សំណង់ និងខ្សាច់ល្បាយភក់នាំចេញក្រៅប្រទេស និងប្រកាសអន្តរក្រសួង លេខ ១៧២ ឧរថ.អគរ.ប្រក និងលេខ ២៩១ សហវ.ប្រក ចុះ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកំណត់ថ្លៃចុះបញ្ជីពាក្យសុំ (កម្រៃអាជ្ញាបណ្ណ) ការពន្យារបន្តការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណធនធានរ៉ែ ឈ្នួលដីប្រចាំឆ្នាំ នៃតំបន់សម្បទានសម្រាប់ការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែ និងសួយសារធនធានរ៉ែ ប្រការ ១ ចំណុចទី៦ (សួយសារលើតម្លៃធនធានរ៉ែ) និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១.-**

អង្គភាពពាក់ព័ន្ធក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងរ៉ែ និងថាមពល ព្រមទាំង រូបវន្តបុគ្គល នីតិបុគ្គល និងសម្បទានិក ដូចក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្ត តាមប្រកាសអន្តរក្រសួងនេះឲ្យមានប្រសិទ្ធភាព ។

**ប្រការ ១២.-**

ប្រកាសនេះ មានប្រសិទ្ធភាព និងចូលជាធរមាន ចាប់ពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៥ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងរ៉ែ និងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល៖**
- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រាជធានី-ខេត្ត
- ដូចប្រការ ១១ (ដើម្បីអនុវត្ត)
- ឯកសារ -កាលប្បវត្តិ